# របៀបមើលធាតុ និង ផ្សំសម្ពង្ស

+ដើម្បីចង់ដឹងរើសរកគូរព្រេង តើល្អឬអាក្រក់យ៉ាងណានោះ ជាដំបូងត្រូវមើលពីឆ្នាំឱ្យដឹងថា ជា ឆ្នាំអ្វី ធាតុអ្វី និង ពង្សអ្វី ដូចមាននៅក្នុងតារាង ខាងក្រោមនេះ :

| ឈ្មោះឆ្នាំ | នាមសត្វ | ធាតុ | ពង្ស |
|---|---|---|---|
| ១- ឆ្នាំជូត | កណ្តុរ | ទឹក | ទេព្តាប្រុស |
| ២- ឆ្នាំឆ្លូវ | គោ | ដី | មនុស្សប្រុស |
| ៣- ឆ្នាំខាល | ខ្លា | ឈើ | យក្សស្រី |
| ៤- ឆ្នាំថោះ | ទន្សាយ | ឈើ | មនុស្សស្រី |
| ៥- ឆ្នាំរោង | នាគ | មាស | ទេព្តាប្រុស |
| ៦- ឆ្នាំម្សាញ់ | ពស់ | ភ្លើង | មនុស្សប្រុស |
| ៧- ឆ្នាំមមី | សេះ | ភ្លើង | ទេព្តាស្រី |
| ៨- ឆ្នាំមមែ | ពពែ | មាស | ទេព្តាស្រី |
| ៩- ឆ្នាំវក | ម៉មែ | ដែក | យក្សប្រុស |
| ១០-ឆ្នាំរកា | ស្វា | ដែក | យក្សប្រុស |
| ១១-ឆ្នាំច | មាន់ | ដី | យក្សស្រី |
| ១២-ឆ្នាំកុរ | ជ្រូក | ទឹក | មនុស្សស្រី |

## ភពកំណើត

សិទ្ធិការ្យ បើអ្នកណាកើតក្នុងថ្ងៃអាទិត្យ មកពីស្រុកក្លិង្គ្រាស្ត្រ មានរោគក្របាត់ ចិត្តក្លាហានមោះ មុត ។ បើអ្នកណាកើតក្នុងថ្ងៃច័ន្ទ មកពីនគរនាគរាជ និងមានតេជះច្រើន ។ បើអ្នកណាកើតក្នុងថ្ងៃអង្គារ មមកពីស្រុកតាបននរក មានកម្លាំងមួនមាំ យកអាសារនាយចៅហ្វាយ និងឫធ្វើសង្គ្រាមល្អណាស់ ។ បើអ្នកណាកើតក្នុងថ្ងៃពុធ មកពីស្រុកលង្កាទ្វីប មានសតិបញ្ញាច្រើន ។ បើអ្នកណាកើតក្នុងថ្ងៃព្រហស្បតិ៍ មកពីឋានសួគ៌ និងមានបុណ្យវាសនាច្រើន ។ បើអ្នកណាកើតក្នុងថ្ងៃសុក្រ មកពីស្រុកឧត្តរកុរុទ្វីប ជាមធ្យម ។ បើអ្នកណាកើតក្នុងថ្ងៃសៅរ៍ មកពីមគ្គប្រទេស មានតេជះក្លាហាន ។

## ជាតិកំណើត

| | |
|---|---|
| បើកើតថ្ងៃអាទិត្យ | ជាស្បែកកណ្ដុរ |
| ថ្ងៃចន្ទ | ស្បែកគោ |
| ថ្ងៃអង្គារ | ស្បែកខ្លា |
| ថ្ងៃពុធ | ស្បែកទន្សាយ |
| ថ្ងៃព្រហស្បតិ៍ | ស្បែកនាគរាជ |
| ថ្ងៃសុក្រ | ស្បែកពស់ |
| ថ្ងៃសៅរ៍ | ស្បែកនាគរាជ |

បើកើតឆ្នាំជូត ជាឆ្អឹងកណ្ដុរ ។ ឆ្នាំឆ្លូវ ឆ្អឹងគោ ។ ឆ្នាំខាល ឆ្អឹងខ្លា ។ ឆ្នាំថោះ ឆ្អឹងទន្សាយ ។ ឆ្នាំ រោង ឆ្អឹងនាគ ។ ឆ្នាំម្សាញ់ ឆ្អឹងពស់ ។ ឆ្នាំមមី ឆ្អឹងសេះ ។ ឆ្នាំមមែ ឆ្អឹងពពែ ។ ឆ្នាំវក ឆ្អឹងស្វា ។ ឆ្នាំរកា ឆ្អឹងមាន់ ។ ឆ្នាំ ច ឆ្អឹងសុខន ។ ឆ្នាំកុរ ឆ្អឹងជ្រូក ។

ឱ្យមើលថ្ងៃនិងឆ្នាំ បើស្បែកនិងឆ្អឹងដូចគ្នា ឬល្មមគ្រប់ដណ្ដប់គ្នាបាន ត្រូវទាយថា អ្នកនោះបាន សេចក្ដីសុខគ្រប់គ្រងខ្លួនឯងបាន ។ បើស្បែកនិងឆ្អឹងគ្របដណ្ដប់គ្នាមិនជិតទេ ទាយថា អ្នកនោះគ្រប់គ្រង រក្សាខ្លួនឯងមិនបានឡើយ ។ តិចតាំងខាងក្រោម រួចហើយត្រូវយកចំនួនទាំងពីរនេះសងគ្នាតាមវិធីលេខ សង ឃើញចំនួនប៉ុន្មានត្រូវយកទាយដូចតទៅនេះ :

បើសល់លេខ ១-២-៥-៩ នឹងស្រឡាញ់គ្នារហូត ដូចមាតាបិតា និងបុត្រធីតា ។

បើលេខ ៣-៤-៦ នឹងស្រឡាញ់គ្នាដូចមិត្តភក្ដិ ។

សល់លេខ ៧-៨-១០ នឹងកើតមានវាយដំច្រំធាក់ ទាស់ទែងខ្វែងគំនិតគ្នាជាប្រាកដ ។

សល់លេខ ១១-១២-១៣ ច្រើនតែជជែកខ្វែងគំនិត និងពាក្យសំដីគ្នា ។

សល់លេខ ១៤-១៥-១៦ ច្រើនតែបែកបាក់ព្រាត់ប្រាសគ្នា ។